# សូមស្វាគមន៍ការមកដល់ដែនជម្រកតាមឆ្នេរ និងឧទ្យានប្រជាជនទន្លេ
# Duwamish River

អ្នកកំពុងនៅលើច្រាំង dx$^w$dəw (DOOwh-duhw), ដែលជាទន្លេ Duwamish River នៅជិតទីតាំងដូនតា ដែលគេហៅថា x$^w$apičəd (wha-PEE-chud). ពាក្យ tx$^w$əlšucid (Lushootseed) នេះមានន័យថា កន្លែងដែលគេគ្រវែងអ្វីមួយ។ ជនជាតិ Coast Salish (ខូស្តសាលិស) ដែលចង់ឆ្លងទន្លេ បានគ្រវែងឈើពីរបីដុំទៅក្នុងទឹកដើម្បីវាយតម្លៃកម្លាំងនៃទឹកទន្លេ និងចរន្តជំនោរទឹក។បើឈើអណ្តែតផ្លាស់ទីយឺតៗ កន្លែងមានជំនោររាក់គឺអាចលុយទឹកឆ្លងបានដោយសុវត្ថិភាពដែលជាផ្លូវកាត់ឆ្លងទន្លេ។

ទន្លេ Duwamish River និងដីដែលទឹកទន្លេនេះហូរកាត់ទៅកាន់សមុទ្រ គឺជាកន្លែងដូនតា និងជាកន្លែងស្នូចត្រីរបស់កុលសម្ព័ន្ធឥណ្ឌា Muckleshoot (មុកខ្លេស៊ុត) កុលសម្ព័ន្ធ Suquamish (ស៊ូក្វាមិស) និងជនជាតិដើម Coast Salish (ខូស្តសាលិស) ដែលត្រូវបានការពារដោយសន្ធិសញ្ញា។ ដូចគ្នានឹងទឹកទន្លេដែរ ភាសាលូស៊ូតស៊ីដ ដែលគេនិយាយរួមគ្នានៅទីនេះបង្រួបបង្រួមជនជាតិនានានៅទីនេះ។ ពួកគេចងក្រងគ្នាតាមរយៈជីវិតជាអ្នកមើលការខុសត្រូវដែលជាជនជាតិដើម ទាំងនៅអតីតកាល បច្ចុប្បន្ន និងអនាគត។ យើងគោរពដី និងទឹកទាំងនេះ ដែលទ្រទ្រង់សហគមន៍របស់យើង ហើយយើងទទួលស្គាល់កន្លែងនេះជាជីវិត និងការលូតលាស់។

## ត្រួសៗអំពីទន្លេ

កាលនោះ ទន្លេ Duwamish River ពត់ពេនឆ្លងកាត់ច្រកពាមនៃជ្រលងភ្នំ Duwamish Valley។ ទឹក និងច្រាំងរបស់វាធ្លាប់សម្បូរទៅដោយជម្រកសម្រាប់ត្រី និងសត្វព្រៃ។ ឧស្សាហកម្មបានលូតលាស់នៅដៃសមុទ្រ Puget Sound នៅដើមសតវត្សរ៍ទី 20។ ផ្លូវទឹកទន្លេបត់បែនរាក់ៗ និងវាលទំនាបលិចទឹកបានត្រូវជំនួសដោយព្រែកជីកនាវាចរណ៍ ត្រង់ភ្លឹង និងជ្រៅៗ។ ឆ្នេរទន្លេប្រវត្តិសាស្ត្របានត្រូវចាក់បំពេញ និងសាងសង់ដើម្បីសម្រួលដល់ការប្រើប្រាស់ខាងឧស្សាហកម្ម។

ឧទ្យានសាធារណៈនេះត្រូវបានរចនាឡើងដើម្បីគ្រាប់តាមដែនជម្រកនៅតាមពាមដែលបានដុះដាលនៅក្នុងទន្លេពីដើម។ រូបភាពភូមិសាស្ត្រអំពីភាពបត់បែននៃបឹងរាងដូចស្រះអូដែលជាប្រវត្តិសាស្ត្រ លេចឡើងម្តងទៀតជាទម្រង់កោងនៅលើទីតាំងបច្ចុប្បន្ន។ កំណាត់ឈើធំៗដែលបានស្រង់ពីផ្លូវទឹកនៅក្បែរនោះជួយទប់ និងរក្សាស្ថិរភាពឆ្នេរទន្លេដែលបានស្តារឡើងវិញដែលទ្រទ្រង់ដោយដើមឈើ និងឈើគុម្ពោតដើមកំណើត។ រុក្ខជាតិតាមវាលភក់បានដាំដុះមកវិញ ដើម្បីផ្តល់ជាអាហារ និងទីជម្រកដល់ត្រី និងសត្វព្រៃដែលរស់នៅស្រាប់ និងដែលផ្លាស់ទីមក ជាពិសេសប្រភេទត្រីសាម៉ុងដូចជាsacəd (SAH-tsub) ឈីនុកជាដើម។ ត្រីសាម៉ុងទាំងនេះបង្កើតបានជាមូលដ្ឋាននៃរបបអាហារសម្រាប់ត្រីបាឡែនពិឃាតដែលជិតផុតពូជ ហើយតំបន់ជម្រកពិសេសបែបនេះជួយក៏ការពារសត្វសមុទ្ររបស់យើងដែរ។

## ការស្វែងរកផ្លូវរបស់អ្នក

ផ្លូវដើរ កន្លែងមើលទន្លេ និងផែផ្តល់ឱ្យអ្នកទស្សនានូវបទពិសោធន៍ដោយផ្ទាល់ជាមួយទន្លេ Duwamish River និងជម្រកត្រីសាម៉ុងដែលបានការពារ ដោយសង្កេតមើលជម្រកសត្វ និងរុក្ខជាតិដែលបានស្តារឡើងវិញ។ ស្វែងយល់អំពីការសម្អាត និងការស្តារឧទ្យាន ហើយឃើញផ្ទាល់ភ្នែកនូវទំនាក់ទំនងរវាងសហគមន៍ដែលមានសុខភាពល្អ និងបរិស្ថានដែលធន់។ សូមរីករាយជាមួយឧទ្យានរបស់អ្នក! សម្រាប់ព័ត៌មានបន្ថែម និងការណែនាំជាសំឡេងអំពីទីតាំងនេះ សូមចូលមើលវេបសាយរបស់យើង។




Port of Seattle